ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការបឋម (Soft Launch)
# កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"

ថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤
នៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប

***សូមគោរព៖***

**ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្ដីសោមនស្សរីករាយក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការបឋម **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"**។ ការជ្រើសរើសខេត្តសៀមរាបជាទីតាំងប្រារព្ធពិធី គឺដោយសារខេត្តសៀមរាបជាគោលដៅទេសចរណ៍សំខាន់ឈានមុខប្រកបដោយភាពសម្បូរបែប ដែលជាបេតិកភណ្ឌវប្បធម៌ ឆ្លុះបញ្ចាំងពីអរិយធម៌ខ្មែរ និងលើកស្ទួយកិត្តិនាមកម្ពុជាក៏ដូចជាផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរពិភពលោក ចាប់អារម្មណ៍មកទស្សនា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងពិធី នាថ្ងៃនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ លោកប្រធានសមាគមធនាគារនៅកម្ពុជា និងតំណាងវិស័យទេសចរណ៍ សម្រាប់ការថ្លែងនូវចំណាប់អារម្មណ៍ ប្រកបដោយអត្ថន័យ។

អង្គពិធីជាទីមេត្រី! ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជ្រាបថា ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងៗទៀត របស់ធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ប្រកបដោយនវានុវត្តន៍ សុវត្ថិភាព និងប្រសិទ្ធភាព សម្រួលការទូទាត់ពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុងប្រទេស និងក្នុងតំបន់។ ដោយពិនិត្យឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគង ដែលមានមុខងារជាប្រព័ន្ធទូទាត់កន្លោង កាលពីខែតុលា ឆ្នាំ២០២០ និងមានការគាំទ្រយ៉ាងច្រើនពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ការដាក់ឱ្យដំណើរការប្រព័ន្ធបាគង ជាការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុបន្ថែមទៀត សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់ឆ្លងគ្រឹះស្ថានទៅវិញទៅមក



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

(Interoperability)។ ស្ថិតក្នុងបរិបទទទួលរងវិបត្តិកូវីដ-១៩ ការទូទាត់ជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង បាន រួមចំណែកជួយគាំពារដល់សុខុមាលភាពសង្គម និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានរក្សា គម្លាតបុគ្គលក្នុងការទូទាត់ជាអេឡិចត្រូនិកពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ (P2P) ដែលកាត់បន្ថយការគំរាមកំហែង ពីជំងឺនេះមកលើសេដ្ឋកិច្ច ព្រោះអតិថិជននៅតែអាចទូទាត់ទំនិញអនឡាញពីចម្ងាយ ហើយប្រព័ន្ធបាគង ក៏បានផ្តល់ជម្រើសច្រើន ងាយស្រួលសម្រាប់អតិថិជនក្នុងការធ្វើប្រតិបត្តិការ ដាក់ប្រាក់/ដកប្រាក់ ចេញ-ចូល គណនីធនាគារ និងអ៊ីវ៉ាឡេត ទៅវិញទៅមក។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ នេះ ប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៧២ គ្រឹះស្ថាន ក្នុងនោះ មានគ្រឹះស្ថានចំនួន ៦០ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ១២ ទៀតបាននិងកំពុងបន្តធ្វើ សន្ធានកម្មប្រព័ន្ធ។ ចំពោះប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគង មានចំនួន ២២២,៨៣ លានប្រតិបត្តិការ (ក្នុងនោះ ៩៨,០៥ លានប្រតិបត្តិការ ជាប្រាក់រៀល និង ១២៤,៣៨ លាន ប្រតិបត្តិការ ជាប្រាក់ដុល្លារអាមេរិក) និងមានទំហំជាប្រាក់រៀលចំនួន ៧៧,៣៦ ទ្រីលានរៀល និងជាប្រាក់ ដុល្លារអាមេរិកចំនួន ៩៦,៣៣ ប៊ីលានដុល្លារអាមេរិក។ ផ្អែកលើទិន្នន័យខាងលើបង្ហាញថា ប្រតិបត្តិការទូទាត់ សងប្រាក់ជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង និងKHQR ទទួលបានការពេញនិយមក្នុងការប្រើប្រាស់យ៉ាង ឆាប់រហ័សក្នុងចំណោមសាធារណជន ដែលបានលើកទឹកចិត្តឱ្យធនាគារជាតិនៃកម្ពុជាបន្តអភិវឌ្ឍប្រព័ន្ធបាគង នៅក្នុងជំហានបន្ទាប់ ក្រោយពីបានដាក់ដំណើរការប្រកបដោយភាពជោគជ័យ ដើម្បីឱ្យប្រព័ន្ធបាគងអាចបំពេញ មុខងារកាន់តែសម្បូរបែប អាចសម្រួលដល់សាធារណជនជាតិ និងអន្តរជាតិ ធ្វើប្រតិបត្តិការទូទាត់ឌីជីថល ប្រកបដោយបរិយាបន្ន។

ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍ **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"** និងប្រកាសដាក់ឱ្យប្រើប្រាស់នៅពេលបន្តិចទៀតនេះ។ ការដាក់ឱ្យដំណើរការ **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"** នាពេលនេះ មានគោលបំណងលើកកម្ពស់សេវាទូទាត់នៅកម្ពុជាឱ្យកាន់តែប្រសើរ រួមចំណែកគាំទ្រវិស័យទេសចរណ៍នៅកម្ពុជា តាមរយៈការជួយសម្រួលដល់ការទូទាត់ជាឌីជីថលលើថ្លៃ ទំនិញ និងសេវារបស់ភ្ញៀវទេសចរអន្តរជាតិដែលអញ្ជើញមកកម្សាន្តនៅប្រទេសកម្ពុជា។ ភ្ញៀវទេសចរអន្តរជាតិ ដែលមកកម្សាន្តនៅក្នុងប្រទេសកម្ពុជា អាចធ្វើការទាញយក **កម្មវិធីទូទាត់បាគងទេសចរ (Bakong Tourist App)** និងចុះឈ្មោះប្រើប្រាស់តាមវិធីងាយៗ ហើយបន្ទាប់មកអាចបញ្ចូលទឹកប្រាក់ក្នុងគណនីបាគង ជាការស្រេច (ចំពោះជំហានបន្ទាប់ កម្មវិធីបាគងទេសចរ អាចភ្ជាប់ជាមួយប័ណ្ណទូទាត់អន្តរជាតិដែលពួកគាត់មាន ដើម្បី ដាក់ប្រាក់ក្នុងគណនីបាន)។ ការណ៍នេះ នឹងកាត់បន្ថយបញ្ហាលំបាកដល់ភ្ញៀវទេសចរក្នុងការប្រើប្រាស់ សាច់ប្រាក់ ដោយគ្រាន់តែធ្វើការស្កេនទូទាត់នៅតាមហាងទំនិញប្រមាណ ៣.៣លានទីតាំង ដែលមានសញ្ញា KHQR code។

**ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា!**

សមិទ្ធផលដែលសម្រេចខាងលើនេះ អាស្រ័យដោយធនាគារជាតិនៃកម្ពុជា បានអនុវត្តកម្មវិធីកំណែទម្រង់ជាបន្តបន្ទាប់លើវិស័យធនាគារ និងស្របពេលដែលប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ ព្រមទាំងការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសក្រោមការយកចិត្តទុកដាក់ ការផ្តល់អនុសាសន៍ដ៏ឧត្តុង្គឧត្តមប្រកបដោយទស្សនវិស័យវែងឆ្ងាយនិងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំលេចបន្តិចទាក់ទងនឹងប្រវត្តិសាស្ត្ររបស់អាណាចក្រខ្មែរដែលមានអាយុកាលយូរលង់ណាស់មកហើយ ដែលជាអាណាចក្រមួយនៅក្នុងចំណោមអាណាចក្រដែលមានឥទ្ធិពលបំផុតនៅអាស៊ីអាគ្នេយ៍ ប៉ុន្តែដោយសារតែសង្គ្រាមឥតឈប់ឈរ ទើបធ្វើឱ្យប្រទេសយើងក្លាយទៅជាប្រទេសដ៏អភ័ព្វមួយ។ មូលហេតុនៃការកើតសង្គ្រាម គឺដោយសារតែការបែកបាក់សាមគ្គីផ្ទៃក្នុង ការស្តាប់និងជឿតាមពាក្យញុះញង់ពីអ្នកដទៃ ហើយងាកមកបំផ្លាញជាតិឯង ធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសនិងសេដ្ឋកិច្ចជាតិ។ នេះជាបទពិសោធដ៏ជូរចត់ ដែលអ្នកនយោបាយកម្ពុជា គួរសិក្សាស្វែងយល់ និងចៀសវាងឱ្យបាន ព្រោះថាសន្តិភាពមានតម្លៃមិនអាចកាត់ថ្លៃបាន។ មានសន្តិភាព ទើបមានការអភិវឌ្ឍលើគ្រប់វិស័យ ដែលអនុញ្ញាតឱ្យយើងអាចរស់នៅដោយគ្មានការភ័យខ្លាច មានអាហារទទួលទានគ្រប់គ្រាន់ មានជម្រកស្នាក់នៅសមរម្យ មានឱកាសទទួលបានការអប់រំ មានសិទ្ធិប្រតិបត្តិជំនឿសាសនា មានលទ្ធភាពចូលរួមសកម្មភាពសង្គមផ្សេងៗ និងអាចធ្វើដំណើរកម្សាន្តក្នុងឱកាសពិធីបុណ្យនានា ទាំងក្នុងនិងក្រៅប្រទេស។ ថ្មីៗនេះ មានការបំផុសបំផុលនិងញុះញង់ពីក្រុមជ្រុលនិយមទាក់ទងនឹងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ (CLV-DTA) បង្កើតឡើងក្នុងឆ្នាំ១៩៩៩ ដែលធ្វើឱ្យសាធារណជនមានការខឹងសម្បាមកកាន់រាជរដ្ឋាភិបាលនិងមានការព្រួយបារម្ភលើការខាតបង់ប្រយោជន៍នានា ជាពិសេសទឹកដី។ តាមពិតទៅ កិច្ចព្រមព្រៀងនេះគ្រាន់តែអនុញ្ញាតឱ្យប្រទេសទាំងបីធ្វើសហប្រតិបត្តិការជាមួយគ្នា ក្នុងនាមប្រទេសជិតខាង ដើម្បីពន្លឿនការអភិវឌ្ឍ ដោយប្រទេសនីមួយៗគ្រប់គ្រងតែទឹកដីរបស់ខ្លួនឯងប៉ុណ្ណោះ មិនមានការបាត់បង់ទឹកដីដូចការបំភ្លៃព័ត៌មានមួយចំនួនពីអ្នកវិភាគគ្មានមូលដ្ឋាននោះទេ ព្រោះទឹកដីកម្ពុជានៅតែជារបស់កម្ពុជា។ ម្យ៉ាងទៀត គម្រោងនេះនឹងជួយផ្តល់អត្ថប្រយោជន៍ជាច្រើន ដែលជួយលើកស្ទួយវិស័យសេដ្ឋកិច្ច វិស័យពាណិជ្ជកម្ម និងវិស័យទេសចរណ៍ រួមទាំងវិស័យផ្សេងៗជាច្រើនទៀត ជាពិសេសជួយសម្រួលដល់ជីវភាពបងប្អូនប្រជាពលរដ្ឋដែលរស់នៅខេត្តជាប់ព្រំដែនឱ្យកាន់តែមានភាពប្រសើរឡើង។ ដូច្នេះ សូមភ្ញៀវកិត្តិយសដែលមានវត្តមាននៅទីនេះ និងសាធារណជនកុំស្តាប់និងជឿតាមការញុះញង់ យើងត្រូវចេះរួបរួមសាមគ្គីគ្នា និងសូមបន្តជឿជាក់លើរាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេសកម្ពុជាឲ្យកាន់តែរីកចម្រើនខ្លាំងថែមទៀត ក្រោមដំបូលសុខសន្តិភាពដែលមាន **សម្តេចតេជោ** ជាអគ្គស្ថាបនិកដ៏ឆ្នើម និងក្រោមការដឹកនាំរាជរដ្ឋាភិបាលដោយ **សម្តេចមហាបវរធិបតី** ជានាយករដ្ឋមន្ត្រី។

ខ្ញុំជឿជាក់ថា ការដាក់ឱ្យដំណើរការបឋម **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"** ដែលប្រព្រឹត្តទៅនាថ្ងៃនេះ នឹងរួមចំណែកជំរុញនវានុវត្តន៍និងបច្ចេកវិទ្យាហិរញ្ញវត្ថុ លើការប្រើប្រាស់សេវាធនាគារ និងហិរញ្ញវត្ថុ និងអាចផ្តល់នូវបទពិសោធក្នុងការទូទាត់ឌីជីថល ប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្ន ដើម្បីឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

ក្នុងនាមធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារ និងស្ថាប័នពាក់ព័ន្ធ ដែលបានយកចិត្តទុកដាក់បំពេញការងារប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រប់តួអង្គពាក់ព័ន្ធ ចូលរួមផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"** ឱ្យបានទូលំទូលាយ ដើម្បីទាញប្រយោជន៍ឱ្យអស់លទ្ធភាពពីការប្រើប្រាស់សមិទ្ធផល ដែលបានដាក់ឱ្យដំណើរការក្នុងថ្ងៃនេះ។ នាពេលឆាប់ៗខាងមុខ បន្ទាប់ពីការដាក់ដំណើរការបឋមបានជោគជ័យ ខ្ញុំសង្ឃឹមថា ភ្ញៀវទេសចរនឹងកាន់តែស្វែងយល់ពីអត្ថប្រយោជន៍នៃកម្មវិធីទូទាត់នេះ ហើយវានឹងក្លាយជាជម្រើសដ៏ប្រសើរនៃមធ្យោបាយទូទាត់ថ្មី ប្រកបដោយភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនានៅប្រទេសកម្ពុជា។

ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលតែងតែផ្តល់កិច្ចសហការ និងការគាំទ្រដល់បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា នៃអង្គពិធីទាំងមូល សូមប្រកបដោយសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការបឋម **កម្មវិធីទូទាត់បាគងទេសចរ "Bakong Tourist App"** ចាប់ពីពេលនេះតទៅ! **សូមអរគុណ**!